## III.កម្មសិទ្ធិរបស់បំប្លែងឡាប្លាស ក្នុង $E_0$

### ការរំឭក

នៅក្នុងប្រព័ន្ធដែលមានបំប្លែងឡាប្លាសទាំងពួង ត្រូវយល់ ដោយមិនចាំបាច់បញ្ជាក់ គឺថា៖ p នៅក្នុងចន្លោះដែល បំប្លែងឡាប្លាសទាំងនោះ មានកំនត់ ទាំងអស់គ្នា ។

### A. **លីនេអារីតេ** ( linéarité)

បើ $f$ និង $g$ ជាធាតុនៃ $E_0$ ដែលមានបំប្លែងឡាប្លាស F និង G ហើយបើ $\propto$ និង $\beta$ ជាចំនួន កុំផ្លិចជាទូទៅ នោះបំប្លែងឡាប្លាស នៃអនុគមន៍ $h = \propto f + \beta g$ គឺ $H = \propto F + \beta G$ .

អនុគមន៍ H កំនត់ក្នុងចន្លោះ $]\sigma(h); +\infty[$ ដោយ $\sigma(h)$ ជាចំនួនពិតដែលធំជាងគេក្នុងចំណោមចំនួនពិតនៃ**ស្វ័យគុណ នៃអនុគមន៍មានក្នុង** $f$ និង $g$ ។

កម្មសិទ្ធនេះ អាចបង្ហាញបានដោយសំអាកលើ លីនេអារីតេ នៃអាំងតេក្រាលទូទៅ (ដោយសន្មតថាអាំងតេក្រាលទាំងនោះ រួមតែមួយ (convergente)) ។

$$\mathcal{L}[\propto f + \beta g](p) = \alpha\, \mathcal{L}[f](p) + \beta\, \mathcal{L}[g](p)$$

រឺ

$$\propto f(t) + \beta g(t) \supset \propto F(p) + \beta G(p)$$

ឧទាហរណ៍

ចូររកបំប្លែងឡាប្លាស នៃអនុគមន៍ $f$ និង $g$ កំណត់ដោយ ៖

$f(t) = (\cos(t))U(t)$ និង $g(t) = (\sin(t))U(t)$

យើងបាន៖

$h_1$(t)= $e^{it}\, U(t)$ និង $h_2$(t) = $e^{-it}\, U(t)$ ។ យើងបានដោយ (F-2-D-02)

$H_1$ (p) = $\frac{1}{p-i}$ ដោយ $\sigma(h_1) = 0$ និង $\mathcal{L}(h_1) = H_1$

និង

$H_2$(p) = $\frac{1}{p+i}$ ដោយ $\sigma(h_2) = 0$ និង $\mathcal{L}(h_2) = H_2$

ដោយ $f = \frac{1}{2} h_1 + \frac{1}{2} h_2$ ហើយដោយ លីនេអារីតេ យើងបាន៖

$\mathcal{L}$(f) = $\frac{1}{2}\mathcal{L}(h_1) + \frac{1}{2}\mathcal{L}(h_2) = \frac{1}{2} H_1 + \frac{1}{2} H_2$

ដូច្នេះ ៖

$[\mathcal{L}(f)](p) = \frac{1}{2}\left(\frac{1}{p-i} + \frac{1}{p+i}\right) = \frac{p}{p^2+1}$ ចំពោះ $p > 0$

| |
|---|
| *cos (t). U(t)* $\supset \frac{p}{p^2+1}$ ចំពោះ $p > 0$ |

**( F-3-A-01)**

ក៏ដូចគ្នាដែរ ៖

$g = \frac{1}{2i} h_1 - \frac{1}{2i} h_2$ ហើយដោយ លីនេអារីតេ យើងបាន៖

| |
|---|
| *sin(t).U(t)* $\supset \frac{1}{p^2+1}$ ចំពោះ $p > 0$ |

**( F-3-A-02)**